## ២-សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

**សារាចរលេខ ០០៧ សរន.សហវ.ពដ**

**ស្តីពីការណែនាំអនុវត្តន៍ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន**
**និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ១៩៩៨**

ក្នុងគោលបំណង ដើម្បីរួមចំណែកក្នុងការទប់ស្កាត់អំពីការកេងបន្លំពន្ធអាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជំរាបលោក លោកស្រី ជាប្រធានមន្ទីរពន្ធដារគ្រប់ខេត្ត-ក្រុងឲ្យបានជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ១៩៩៨នេះ គឺត្រូវអនុវត្តចំពោះយានយន្តដែលមានពាក់ផ្លាកលេខ និងមានប័ណ្ណសំគាល់យានយន្តត្រឹមត្រូវពេញ ដោយក្រសួងសាធារណការ និងដឹកជញ្ជូន រីឯយានយន្តពាក់ផ្លាកលេខរាជការ... នគ... និង ខម... គឺត្រូវអនុវត្តចំពោះតែយានយន្តទាំងឡាយណា ដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួងសាមីតែប៉ុណ្ណោះ។

គ្រប់អង្គភាពពន្ធដារ មានភារកិច្ចត្រូវអនុវត្តតាមសារាចរណែនាំនេះឲ្យប្រកបប្រសិទ្ធភាពខ្ពស់ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

***

## ២- ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ប្រកាស**

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

**ប្រកាសលេខ ៦៣៨ ឧក.ប្រក**

* * *

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ២៩៥០/៩៧/កអក ចុះថ្ងៃទី ១២-៩-១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ ១៨៧ ពរអ ចុះថ្ងៃទី ២០-១០-១៩៩៥ របស់សាលាខេត្តកណ្តាល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ្គោ ឡុងតិកស្បៀង ចុះថ្ងៃទី ១០-១១-១៩៩៨